**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**នាយកដ្ឋានព័ត៌មាន**

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃទស្សនកិច្ចផ្លូវការរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋឆែក នៅថ្ងៃទី ១៣-១៤ ខែតុលា ឆ្នាំ២០១៩

---

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបំពេញទស្សនកិច្ចផ្លូវការប្រកបដោយជោគជ័យ នៅសាធារណរដ្ឋឆែក នៅថ្ងៃទី១៣-១៤ ខែតុលា ឆ្នាំ២០១៩។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានជួបប្រជុំទ្វេភាគីជាមួយឯកឧត្តម អេនដ្រេហ្គ បាប៊ីស (Andrej Babiš) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឆែក ក្នុងបរិយាកាសកក់ក្តៅ និងរួសរាយរាក់ទាក់ ឆ្លុះបញ្ចាំងពីទំនាក់ទំនងទ្វេភាគីដ៏ជិតស្និទ្ធ និងមានជាយូរមកហើយ ដែលបានកសាងឡើងដោយមេដឹកនាំកំពូលនៃប្រទេសទាំងពីរ។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានបំពេញព្រះរាជតួនាទីយ៉ាងសំខាន់ក្នុងការជំរុញទំនាក់ទំនងមិត្តភាព និងកិច្ចសហការដ៏កក់ក្តៅរវាងប្រជាជននៃប្រទេសទាំងពីរ។ ក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះជំនួយដ៏ថ្លៃថ្លារបស់រដ្ឋាភិបាលនិងប្រជាជននៃសាធារណរដ្ឋឆែក ដែលបានផ្តល់មកកម្ពុជាក្នុងគ្រាដ៏លំបាកបំផុត បន្ទាប់ពីការរំដោះប្រទេសក្នុងឆ្នាំ១៩៧៩។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានអបអរសាទរយ៉ាងកក់ក្តៅចំពោះសាធារណរដ្ឋឆែក ដែលទទួលបានជោគជ័យក្នុងផ្នែកសេដ្ឋកិច្ចរបស់ខ្លួន ពោលគឺជាប្រទេសមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតនៅក្នុងតំបន់ ដែលមានអត្រាអ្នកគ្មានការងារធ្វើទាប។ សម្តេចតេជោនាយករដ្ឋមន្ត្រី មានការជឿជាក់យ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ ឯកឧត្តម អេនដ្រេហ្គ បាប៊ីស នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឆែក ប្រជាជននៃសាធារណរដ្ឋឆែក នឹងបន្តទទួលបានសន្តិភាព វឌ្ឍនភាព និងវិបុលភាព។

នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានពិនិត្យឡើងវិញដោយក្តីពេញចិត្ត ចំពោះការអភិវឌ្ឍនៃទំនាក់ទំនងកម្ពុជា-ឆែក និងវឌ្ឍនភាពដែលសម្រេចបានក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីជាផលប្រយោជន៍រួមសម្រាប់



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 216 341
អ៊ីមែល : mfaic@mfaic.gov.kh

ប្រជាជននៃប្រទេសទាំងពីរ និងបានប្តេជ្ញាចិត្តធ្វើឲ្យស៊ីជម្រៅបន្ថែមទៀតនូវចំណងមិត្តភាព និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ សុខាភិបាល រ៉ែ ថាមពល កសិកម្ម និងវប្បធម៌។

នាយករដ្ឋមន្ត្រីទាំងពីរបានផ្លាស់ប្តូរយោបល់ និងឯកភាពគ្នាលើការលើកកម្ពស់កិច្ចសហប្រតិបត្តិការលើបញ្ហាតំបន់និងអន្តរជាតិដែលមានការយកចិត្តទុកដាក់ទៅវិញទៅមក។ មេដឹកនាំទាំងពីរបានទទួលស្គាល់អំពីសារៈសំខាន់នៃការលើកកម្ពស់កិច្ចសហប្រតិបត្តិការពហុភាគី និងកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីសន្តិភាព និងសមាហរណកម្មពិភពលោក ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍពិភពលោក។

មេដឹកនាំទាំងពីរបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការជំរុញកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគី និងបានកត់សម្គាល់ដោយរីករាយនូវទំហំពាណិជ្ជកម្មដែលកើនឡើងរវាងប្រទេសទាំងពីរក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ។ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងវិស័យនេះឱ្យមានការរីកចំរើនថែមទៀត ភាគីទាំងពីរបានជំរុញឲ្យក្រសួងពាណិជ្ជកម្មនៃប្រទេសទាំងពីរ ពិនិត្យលទ្ធភាពនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការសេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស រវាងប្រទេសទាំងពីរនាពេលឆាប់ខាងមុខ។

ភាគីទាំងពីរក៏បានសង្កត់ធ្ងន់ផងដែរពីតួនាទីសំខាន់របស់វិស័យឯកជន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងលើកទឹកចិត្តឱ្យមានកិច្ចសហការជិតស្និទ្ធរវាងសភាពាណិជ្ជកម្មកម្ពុជា និងសភាពាណិជ្ជកម្មសាធារណរដ្ឋឆែក ក្នុងការទាញយកផលប្រយោជន៍ពីសក្តានុពលសេដ្ឋកិច្ច និងឱកាសធុរកិច្ចរបស់ប្រទេសទាំងពីរ។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាល និងប្រជាជននៃសាធារណរដ្ឋឆែក ចំពោះការលុបចោល និងការបង្វែរបំណុលទៅជាជំនួយអភិវឌ្ឍន៍សម្រាប់ប្រទេសកម្ពុជា។ ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងប្រទេសកម្ពុជានិងសាធារណរដ្ឋឆែក បានចង្អុលបង្ហាញពីបំណងប្រាថ្នារបស់ប្រទេសទាំងពីរ ក្នុងការពង្រឹងចំណងមិត្តភាព និងបន្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដើម្បីផលប្រយោជន៍នៃប្រជាជនទាំងពីរ។

រំលឹកឡើងវិញនូវទំនាក់ទំនងជាប្រវត្តិសាស្ត្រ សេដ្ឋកិច្ច និងវប្បធម៌ ដោយផ្អែកលើមិត្តភាព កិច្ចសហប្រតិបត្តិការ ការជឿទុកចិត្តគ្នា និងការយោគយល់គ្នារវាងប្រទេសទាំងពីរ ភាគីទាំងពីរបានឯកភាពគ្នារៀបចំផែនការរួម ដើម្បីអបអរសាទរខួបលើកទី៦៥នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរនៅឆ្នាំ២០២១ ។

ឯកឧត្តមនាយករដ្ឋមន្ត្រី អេនដ្រេហ្គ បាប៊ីស បានសំដែងការកោតសរសើរយ៉ាងខ្លាំងចំពោះការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាចំពោះសន្តិភាព និងស្ថិរភាព ក្រោមការដឹកនាំរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបានដឹកនាំប្រទេសឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយចីរភាព។ ឯកឧត្តមនាយករដ្ឋមន្ត្រី បានបង្ហាញការជឿជាក់យ៉ាងមុតមាំថា ប្រទេសកម្ពុជា នឹងសម្រេចគោលដៅទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ ។ ពាក់ព័ន្ធនឹងដំណើរការនីតិវិធីដកប្រព័ន្ធអនុគ្រោះពន្ធ (គ្រប់មុខទំនិញលើកលែងអាវុធ-EBA) ដោយគណៈកម្មការអឺរ៉ុប ឯកឧត្តមនាយករដ្ឋមន្ត្រី បានចាត់ទុកប្រព័ន្ធអនុគ្រោះពន្ធនេះ ជាជំនួយដែលមានប្រសិទ្ធភាពខ្ពស់ដែលផ្តល់ជូនប្រទេសកំពុងអភិវឌ្ឍ ហើយសង្ឃឹមថា វិធានការបែបនេះដោយគណៈកម្មការអឺរ៉ុប នឹងមិនកើតឡើងឡើយ និងថា កម្ពុជានឹងបង្ហាញវឌ្ឍនភាពប្រកបដោយវិជ្ជមាននៅក្នុងវិស័យសិទ្ធិមនុស្ស។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជម្រាបជូនភាគីមិត្តអំពីស្ថានភាពនយោបាយបច្ចុប្បន្ននៅកម្ពុជា និងបានចង្អុលបង្ហាញថា ការធ្វើបដិវត្តន៍ពណ៌ឬការប៉ុនប៉ងធ្វើរដ្ឋប្រហារនៅកម្ពុជានឹងត្រូវបរាជ័យ។ រាជរដ្ឋាភិបាល នឹងចាត់វិធានតាមផ្លូវច្បាប់និងចាំបាច់នានា ដើម្បីពង្រឹងនីតិរដ្ឋ និងការពារសន្តិភាព ស្ថិរភាព នៅកម្ពុជា ដើម្បីផលប្រយោជន៍ជាតិ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ របស់ប្រទេសកម្ពុជាចំពោះប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្សក្នុងក្របខណ្ឌនីតិរដ្ឋ។

ថ្នាក់ដឹកនាំទាំងពីរបានស្វាគមន៍ការចុះហត្ថលេខាលើឯកសារទ្វេភាគីចំនួនបី ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចផ្លូវការនេះ ដែលមានគោលបំណងជំរុញកិច្ចសហប្រតិបត្តិការបន្ថែមទៀតនៅក្នុងវិស័យសុខាភិបាល ធុរកិច្ច និងការទូត។ ឯកសារទាំងនោះរួមមាន អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាលកម្ពុជា និងភ្នាក់ងារអនុវត្តគម្រោងសុខាភិបាលឆែក VAMED អនុស្សរណៈនៃការយោគយល់គ្នារវាងសភាពាណិជ្ជកម្មកម្ពុជា និងសភាពាណិជ្ជកម្មឆែក និងអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា និងបណ្ឌិតសភាការទូត នៃក្រសួងការបរទេសឆែក។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមនាយករដ្ឋមន្ត្រី អេនដ្រេហ្គ បាប៊ីស** ក៏ដូចជារដ្ឋាភិបាលនិងប្រជាជននៃសាធារណរដ្ឋឆែក ដែលបានទទួលស្វាគមន៍និងបដិសណ្ឋារកិច្ចដ៏កក់ក្តៅចំពោះសម្តេចផ្ទាល់ និងសមាជិកគណៈប្រតិភូកម្ពុជា ក្នុងអំឡុងពេលស្នាក់នៅទីក្រុងប្រាក។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអញ្ជើញ ឯកឧត្តមនាយករដ្ឋមន្ត្រី **អេនដ្រេហ្គ បាប៊ីស** មកបំពេញទស្សនកិច្ចនៅកម្ពុជា នៅពេលវេលាសមស្រប។ ឯកឧត្តមនាយករដ្ឋមន្ត្រី **អេនដ្រេហ្គ បាប៊ីស** បានទទួលយក និងបានថ្លែងអំណរគុណ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចំពោះការអញ្ជើញនេះ។ កាលបរិច្ឆេទនៃដំណើរទស្សនកិច្ចនេះនឹងត្រូវទំនាក់ទំនងគ្នាតាមច្រកការទូត។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានចូលជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម** Jaroslav Kubera ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឆែក។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានកោតសរសើរចំពោះទំនាក់ទំនងទ្វេភាគីដ៏ល្អរវាងស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ និងបានលើកទឹកចិត្តឲ្យស្ថាប័នទាំងពីរពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការនៅក្នុងវេទិកាតំបន់ និងសកលនានា ៕ល.

ថ្ងៃពុធ ០៣ រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៩